**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...០៤៦៣...សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពិនិត្យឈ្មោះផ្ទាល់ខ្លួនរបស់បេក្ខជនដែលមានសិទ្ធិចូលរួមប្រឡងប្រជែង ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែងចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ជ្រាបថា បេក្ខជនទាំងពីរភេទ ត្រូវមកពិនិត្យឈ្មោះផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីសម្រួលដល់ដំណើរការប្រឡងប្រកបដោយភាពរលូននិងមានប្រសិទ្ធភាព ។ ការពិនិត្យឈ្មោះផ្ទាល់ខ្លួននេះមានរយៈពេលចាប់ពីថ្ងៃជូនដំណឹងបិទបញ្ជីឈ្មោះបេក្ខជនរហូតដល់ត្រឹមថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៦ វេលាម៉ោង ៥:០០ នាទីរសៀល ជាកំណត់។

ក្នុងករណីបេក្ខជនមិនបានមកពិនិត្យឈ្មោះផ្ទាល់ខ្លួន និងមិនមានការតវ៉ាក្នុងរយៈពេលដូចបានជម្រាបជូនខាងលើ គណៈកម្មការប្រឡង មិនទទួលខុសត្រូវចំពោះការមិនមានឈ្មោះក្នុងបញ្ជីរាយនាមប្រឡងរបស់បេក្ខជនជាយថាហេតុឡើយ និងចាត់ទុកថា បេក្ខជនបានឯកភាពទាំងស្រុងលើបញ្ជីរាយនាមបេក្ខជនប្រឡងដែលគណៈកម្មការប្រឡងបានបិទផ្សាយនេះ ។

បញ្ជីរាយនាមបេក្ខជន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចូលរួមប្រឡង នឹងមានបិទផ្សាយនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ ឬសាលាជាតិពន្ធដារ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬបេក្ខជនអាចទទួលព័ត៌មាននេះនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh និងគេហទំព័ររបស់នាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ចនិងហិញ្ញវត្ថុ www.pd.mef.gov.kh ឬគេហទំព័ររបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ www.efi.mef.gov.kh ចាប់ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ តទៅ។

ប្លង់មណ្ឌលប្រឡង បញ្ជីរាយនាមបេក្ខជនប្រឡងតាមបន្ទប់ លេខតុ និង បារកូដ នឹងត្រូវបិទផ្សាយនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៦ ចាប់ពីវេលាម៉ោង ៨:០០ នាទីព្រឹក។ បេក្ខជនអាចទំនាក់ទំនងព័ត៌មានបន្ថែមតាមទូរស័ព្ទលេខ០១៧ ៩០៥ ៥០៦/ ០៩២ ៧៣៧ ២៥៥ ក្នុងករណីចាំបាច់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**បញ្ជាក់**: គណៈកម្មការរៀបចំការប្រឡង រក្សាសិទ្ធិក្នុងការកែប្រែសេចក្តីជូនដំណឹងនេះក្នុងករណីចាំបាច់ ។

***ចម្លងជូន:***
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងមុខងារសាធារណៈ*
*-អង្គភាពប្រឆាំងអំពើពុករលួយ*
*"ដើម្បីជូនជ្រាប"*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-អគ្គនាយកដ្ឋានពន្ធដារ*
*-វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-នាយកដ្ឋានបុគ្គលិក នៃកសហវ*
*"សូមមេត្តាជួយផ្សព្វផ្សាយ"*
*-ឯកសារ-កាលប្បវត្តិ*

**គណៈកម្មការប្រឡង**

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....០០១.....សហវ

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០១៦

## បទបញ្ញត្តិ

## សម្រាប់បេក្ខជនប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារជាមន្ត្រីរាជការនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យនៅក្នុងពេលប្រឡងឱ្យប្រព្រឹត្តទៅបានរលូន និងមានប្រសិទ្ធភាព បេក្ខជនត្រូវគោរពបទបញ្ញត្តិនៃការប្រឡង ដូចខាងក្រោម៖

### ១- ប្រការដែលបេក្ខជនត្រូវអនុវត្ត

- ត្រូវយកសលាកប័ត្រឯកត្តជនមកជាមួយនៅពេលប្រឡងជាចាំបាច់
- ត្រូវមកដល់មណ្ឌលប្រឡង យ៉ាងតិច ៣០នាទី មុនដំណើរការប្រឡងចាប់ផ្តើម
- មិនត្រូវអនុញ្ញាតឱ្យចូលក្នុងមណ្ឌលប្រឡង ឬបន្ទប់ប្រឡង ចំពោះបេក្ខជនដែលមកយឺតលើសពី ១៥នាទី
- ត្រូវស្លៀកពាក់សមរម្យ
- ត្រូវយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតសម្គាល់ខ្លួន ដែលមានបិទរូបថត និងមានហត្ថលេខាត្រឹមត្រូវ ក្នុងករណីបេក្ខជនបាត់សលាកប័ត្រឯកត្តជន
- ត្រូវអនុវត្តតាមការណែនាំរបស់អនុគណៈកម្មការមេប្រយោគ អនុគណៈកម្មការអនុរក្ស និងអនុគណៈកម្មការពាក់ព័ន្ធនៃគណៈកម្មការរៀបចំការប្រឡង
- ត្រូវរក្សារបៀបរៀបរយ និងភាពស្ងៀមស្ងាត់នៅក្នុងពេលប្រឡង
- ត្រូវប្រើប៊ិចដែលមានទឹកពណ៌ខៀវ ជាប្រភេទប៊ិចក្បាលរុយ *(Ball-point-pen)*
- បេក្ខជនត្រូវបង្កលក្ខណៈងាយស្រួលឱ្យអ្នកមានសមត្ថកិច្ចត្រួតពិនិត្យ ហើយត្រូវគោរពតាមសំណូមពររបស់អ្នកត្រួតពិនិត្យក្នុងការដកហូតទុកនូវសម្ភារៈ ឬរបស់អ្វីៗដែលគ្មានការអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡង
- ត្រូវគោរពបទវិន័យ នៃការប្រឡងដោយមិនត្រូវធ្វើឱ្យខូចរបៀបរៀបរយ និងសណ្តាប់ធ្នាប់នៃការប្រឡងឡើយ ឧទាហរណ៍៖ អង្គុយតាមលេខតុ ដែលអនុរក្សបង្ហាញ សរសេរឈ្មោះនិងលេខតុនៅលើក្បាលសន្លឹកកិច្ចការប្រឡងដែលអនុរក្សចែកឱ្យតាមការណែនាំ និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ ទោះបីជាក្រដាសប្រឡងគ្មានសរសេរចម្លើយ ឬដំណោះស្រាយអ្វីក៏ដោយ។ បេក្ខជនដែលមិនប្រគល់សន្លឹកកិច្ចការប្រឡងជូនអនុរក្សវិញនឹងបានពិន្ទុសូន្យ។

### ២- ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត

- ហាមដាច់ខាតសេពគ្រឿងស្រវឹង
- ហាមយកអាវុធ ឬគ្រឿងផ្ទុះគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡង

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- ហាមយកតាម និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងគ្រប់ប្រភេទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ ដែលមានផ្ទុកឯកសារចូលក្នុងបន្ទប់ប្រឡង
- មិនត្រូវឱ្យអ្នកដទៃប្រឡងជំនួសឡើយ
- ហាមចម្លងពីអ្នកជិតខាង ឬបង្កលក្ខណៈឱ្យអ្នកដទៃចម្លង ឬសរសេរហើយអានខ្លាំងៗ ឮដល់បេក្ខជនដទៃទៀតក្នុងពេលកំពុងធ្វើវិញ្ញាសា
- ហាមប្ដូរសន្លឹកកិច្ចការប្រឡង ដើម្បីឱ្យអ្នកដទៃជួយកែ
- មិនត្រូវស្នើឱ្យអ្នកដទៃជួយពន្យល់
- ហាមប្រើទឹកលុបសម្រាប់លុបកំហុសផ្សេងៗ លើសន្លឹកកិច្ចការប្រឡង
- មិនត្រូវធ្វើឱ្យចលាចលក្នុងមណ្ឌលប្រឡង

***បញ្ជាក់: រាល់ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើ កម្រិតពិន័យត្រូវបានកំណត់ដោយអនុគណៈកម្មការមេប្រយោគ។***

**គណៈកម្មការប្រឡង**

Collection by VCAT Professional Consultant